00273385

C22/5/7

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**សំណុំរឿងលេខ** ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស( អ.ប.ជ ១៧)

**កាលបរិច្ឆេទឯកសារ** ៖ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩

**ភាគីបញ្ជូន** ៖ ការិយាល័យសហព្រះរាជអាជ្ញា

**ភាសាដើម** ៖ ភាសាអង់គ្លេស

**ប្រភេទឯកសារ** ៖ **អត្ថបទជាសាធារណៈបន្ទាប់ពីលុបចេញមួយចំនួន**

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

---

**<u>បញ្ជូនដោយ៖</u>**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**<u>បញ្ជូនទៅ៖</u>**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ ជនត្រូវចោទ/ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Uy

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Uy

C22/5/7

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៧)

## ១. សេចក្ដីផ្ដើម

១. ជនត្រូវចោទ អៀង សារី បានដាក់បណ្ដឹងឧទ្ធរណ៍មួយ ("បណ្ដឹងឧទ្ធរណ៍")[1] ដែលស្វែងរកសុំឲ្យធ្វើការកែប្រែដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបន្តថិរវេលាឃុំខ្លួនបណ្ដោះអាសន្នរូបគាត់មួយរយៈពេលតទៅទៀត ដែលមិនឲ្យលើសពីមួយ(១)ឆ្នាំ ("ដីកាសម្រេចបន្តថិរវេលា")[2] គាត់បានតវ៉ាថា (១) ភស្តុតាងដែលសម្រាប់ចាប់ផ្ដើមការឃុំខ្លួនអនុលោមតាមវិធាន៦៣(៣)(ក) និង៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង គឺមិនត្រូវបានបំពេញគ្រប់គ្រាន់តាមលក្ខណ្ឌតម្រូវទេ[3]។ (២) ការឃុំខ្លួននៅក្នុងលំនៅដ្ឋាន គឺជាជម្រើសដ៏សមហេតុសមផលមួយដើម្បីជំនួសឲ្យការឃុំខ្លួន[4] ហើយនៅក្នុងគ្រប់ករណីទាំងអស់ (៣) សហចៅក្រមស៊ើបអង្កេតមិនបានដឹកនាំការស៊ើបសួរដោយការយកចិត្តទុកដាក់ត្រឹមត្រូវទេ[5] ។

២. សហព្រះរាជអាជ្ញា ស្នើដល់អង្គបុរេជំនុំជម្រះ សូមឲ្យធ្វើការច្រានចោលនូវបណ្ដឹងឧទ្ធរណ៍នេះដោយមូលហេតុដូចមានខាងក្រោមនេះ៖

(ក) ជនត្រូវចោទបានខកខានមិនបានបង្ហាញឲ្យឃើញថា មានការការផ្លាស់ប្ដូរជាក់ស្ដែងណាមួយអំពីកាលៈទេសៈនោះទេ តាំងតែពីរូបគាត់ត្រូវបាន សហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនពីដំបូងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ មក ("ដីកាសម្រេចស្ដីពីឃុំ

---

[1] *ករណីរឿងរបស់ អៀង សារី,* បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១០ ធ្នូ ២០០៨។ C22/5, ERN 00250393-00250412 [*ចាប់ពីនេះតទៅហៅថា* បណ្ដឹងឧទ្ធរណ៍] ។

[2] *ករណីរឿងរបស់ អៀង សារី,* ដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីពីការបន្តថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ វិច្ឆិកា ២០០៨, C22/4, ERN 00238566-00238576 [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចបន្តថិរវេលា] ។

[3] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១ ។

[4] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១ ។

[5] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១ ។

ខ្លួន")[6] និងតាំងពីពេលការឃុំខ្លួននោះត្រូវបានបញ្ជាក់អះអាងថា ត្រឹមត្រូវដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ មក ("សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន")[7] ។ នៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន ដែលបានវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿង ដូចមានក្នុងកាលបរិច្ឆេទរបស់សាលដីកានេះ អង្គបុរេជំនុំជម្រះបានកត់សំគាល់ឃើញថាលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៦៣.៣.ក និង៦៣(៣)(ខ)(៣-៥) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញគ្រប់គ្រាន់ហើយៗ "ការឃុំខ្លួនបណ្តោះអាសន្នផ្អែកលើមូលហេតុ [ទាំងនោះ] គឺនៅតែ [ជា] វិធានការដ៏ចាំបាច់មួយដដែល"[8] ។

(ខ) បច្ចុប្បន្ននេះ ក្នុងសំណុំរឿងមានភស្តុតាង ដែលអាចបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវរបស់អ្នកសង្កេតការណ៍ដែលមិនលំអៀងនៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះថា ដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ដែលបច្ចុប្បន្ននេះរូបគាត់កំពុងតែស្ថិតនៅក្នុងកិច្ចស៊ើបសួរ ។ លើសពីនេះ មានលក្ខខណ្ឌដាច់ដោយឡែកៗពីគ្នាចំនួនបី ក្នុងចំណោមប្រាំ ដែលចាំបាច់តម្រូវឲ្យធ្វើការឃុំខ្លួនអនុលោមតាមវិធាន៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញគ្រប់តាមលក្ខខណ្ឌតម្រូវហើយដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការឃុំខ្លួននេះ ។ ជាក់ស្តែង ការឃុំខ្លួនរបស់ជនត្រូវចោទគឺជាវិធានការដ៏ចាំបាច់ (១) ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។ (២) ដើម្បីការពារសន្តិសុខឲ្យរូបគាត់ ។ (៣) ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

---

[6] *ករណីរឿងរបស់ អៀង សារី,* ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ វិច្ឆិកា ២០០៧, [*ចាប់ពីនេះតទៅហៅថា* ដីកាបង្គាប់ឲ្យឃុំខ្លួន] ។

[7] *ករណីរឿងរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ តុលា ២០០៨, C22/I/73, ERN 00232830-00232861 [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី] ។

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, ការសម្រេចទោស (Disposition) ។

(គ) អង្គបុរេជំនុំជម្រះ បានកត់សំគាល់ឃើញថា ការឃុំខ្លួននៅក្នុងលំនៅដ្ឋាន ឬសូម្បីតែឃុំខ្លួននៅក្នុងមន្ទីរពេទ្យក្តី ក៏ត្រូវបានចេញដីកាសម្រេចរួចហើយដែរ។ គ្មានការផ្លាស់ប្តូរណាមួយទេអំពីកាលៈទេសៈ ដើម្បីឱ្យចេញជាសាលដីកាសម្រេចកែប្រែទៅលើដីកាសម្រេច(មុន) នោះទេ ។ មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នៅតែជាមន្ទីរដែលមានការបំពាក់នូវសម្ភារៈយ៉ាងត្រឹមត្រូវសម្រាប់ឃុំខ្លួនរូបគាត់ដដែល។

ឃ. ការយកចិត្តទុកដាក់ហ្មត់ចត់ ឬមិនមានការយកចិត្តទុកដាក់ហ្មត់ចត់ពីសំណាក់សហចៅក្រមស៊ើបអង្កេត គឺវាមិនពាក់ព័ន្ធទៅនឹងការសម្រេច អនុលោមវិធាន៦៣(៣)(ក) និង ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងនោះទេ ។ (២) តុលាការទាំងឡាយណាដែលចាត់ទុកការយកចិត្តទុកដាក់ ឬមិនយកចិត្តទុកដាក់នេះថា ជាលក្ខណៈវិនិច្ឆ័យកំណត់មួយដើម្បីជំនុំជម្រះលើករណីរឿងក្តីនានាដែលមានលក្ខណៈស្មុគស្មាញនិងទំហំ ដែលខុសប្លែកគ្នាយ៉ាងឆ្ងាយពីតុលាការនេះ ។ និង (៣) តុលាការទាំងឡាយណាដែលធ្វើការដោយប្រើយន្តការនានាសម្រាប់ស៊ើបអង្កេតថ្នាក់ក្រុង ដែលត្រូវបានបង្កើតឡើងច្រើនជាងតុលាការនេះដែលធ្វើការងារដោយប្រើយន្តការស៊ើបអង្កេតមួយថ្មី និងយន្តការដែលបានបង្កើតជាពិសេស ហើយដែលមានបញ្ហាប្រឈមជាច្រើនផង (its attendant challenges) ។ ក្នុងករណីណាក៏ដោយ ការវិភាគទៅលើសំណុំរឿងមិនបានបង្ហាញឱ្យឃើញថា មានការមិនមានការយកចិត្តទុកដាក់ហ្មត់ចត់ណាមួយនោះទេ ។

## ២. សេចក្តីសន្និដ្ឋានបឋម

***មិនតម្រូវចាំបាច់ឱ្យមានសវនាការផ្ទាល់មាត់នោះទេ***

៣. វិធាន៧៧(៣) នៃវិធានផ្ទៃក្នុង (“វិធាន”) អនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ បន្ទាប់ពីពិនិត្យពិចារណាទៅលើទស្សនៈយល់ឃើញរបស់ភាគីទាំងអស់រួចហើយ ត្រូវធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយល័ក្ខណ៍អក្សរតែប៉ុណ្ណោះ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានស្នើឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះទេ ។ នៅពេល

ដែលសហព្រះរាជអាជ្ញា គាំទ្រឲ្យមានសវនាការផ្ទាល់មាត់មួយលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននេះ បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះទាក់ទងតែទៅនឹងការបន្តថិរវេលាដែលត្រូវបានបញ្ជាក់អះអាងថាត្រឹមត្រូវក្នុងពេលថ្មីៗនេះតែប៉ុណ្ណោះ ហើយដូចនេះ មិនមានលើកឡើងនូវទឡ្ហីករណ៍ខាងអង្គហេតុនិងអង្គច្បាប់ណាថ្មីទៀត ដែលចាំបាច់ត្រូវលើកឡើងនៅក្នុងសវនាការផ្ទាល់មាត់មួយនោះទេ ។ អាស្រ័យហេតុនេះ ដើម្បីផលប្រយោជន៍ដល់ការសន្សំសំចៃរបស់តុលាការ សហព្រះរាជអាជ្ញា ស្នើសុំឲ្យអង្គបុរេជំនុំជម្រះ ធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះបានហើយ ។

## ៣. អំពីអង្គច្បាប់

### *ភារកិច្ចក្នុងការផ្តល់ហេតុផលនៅក្នុងដីកាបង្គាប់ឲ្យឃុំខ្លួន*

៤. វិធាន៦៣(៧) នៃវិធានផ្ទៃក្នុង តម្រូវថានៅក្នុងដីកាសម្រេចស្តីពីការបន្តថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត "ត្រូវមានការបញ្ជាក់ពីមូលហេតុ នៃការបន្តថិរវេលាបែបនេះ" ។ មូលហេតុទាំងនេះគឺត្រូវផ្តល់បន្ទាប់ពីបានពិចារណាទៅលើការជំទាស់របស់ជនជាប់ឃុំឃាំងនានា។ ដោយលើកសំអាងទៅលើយុត្តិសាស្ត្រអន្តរជាតិនានាដែលត្រូវបានបង្កើតឡើង អង្គបុរេជំនុំជម្រះ បានរកឃើញថា នៅក្នុងរាល់ដីកាសម្រេចទាំងអស់របស់ស្ថាប័ននានារបស់តុលាការ ដោយរាប់បញ្ចូលទាំងរបស់សហចៅក្រមស៊ើបអង្កេតផង ត្រូវតែផ្តល់មូលហេតុផ្សេងៗ ដើម្បីឲ្យបានស្របទៅតាមបទដ្ឋានអន្តរជាតិ[9] ។

៥. សមត្ថកិច្ចមួយរបស់តុលាការណាមួយ "ត្រូវតែបង្ហាញឲ្យឃើញ តាមរយៈការពិភាក្សានូវរាល់កត្តាទាំងអស់ដែលពាក់ព័ន្ធ" ថាតើចុងចោទបានបំពេញ ឬខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងបន្ទុកទទួលខុសត្រូវរបស់ខ្លួនរបៀបដូចម្តេចខ្លះ ដើម្បីនឹងឲ្យរូបគាត់បានចូល

---

[9] *ករណីរឿងរបស់ នួន ជា,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០៦) ចុះថ្ងៃទី២៨ សីហា ២០០៨, ERN 001210322-00219333, D55/I/8, កថាខណ្ឌទី២១ ។

មកបង្ហាញខ្លួននៅក្នុងពេលសវនាការជំនុំជម្រះក្តី ហើយនឹងមិនបង្កឱ្យមានការគំរាមកំហែងណាមួយដល់ជនរងគ្រោះនិងសាក្សីនានាឬតតិយជននោះ[10] ។ មិនបង្ខំឱ្យសមត្ថកិច្ចនោះត្រូវតែដោះស្រាយលើគ្រប់រាល់កត្តាទាំងអស់ដែលអាចកើតមានឡើងដែលសមត្ថកិច្ចនោះត្រូវយកចិត្តទុកដាក់នៅក្នុងពេលធ្វើសេចក្តីសម្រេចអំពីថា តើចុងចោទនឹងចូលខ្លួន ឬមិនចូលខ្លួននៅក្នុងពេលសវនាការនោះទេ ។ គឺជាការគ្រប់គ្រាន់សម្រាប់ចង្អុលបង្ហាញអំពីរាល់កត្តាពាក់ព័ន្ធទាំងអស់ដែលសមត្ថកិច្ចបានយកចិត្តទុកដាក់នោះហើយ នៅពេលដែលត្រូវឈានទៅដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន[11] ។

## *អំពីលក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន*

៦. ផ្អែកតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឱ្យធ្វើការឃុំខ្លួនបណ្តោះអាសន្ន (ជនត្រូវចោទ) បានតែក្នុងករណីដូចខាងក្រោមនេះ៖

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់ដើម្បី:

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនជាប់ចោទ ឬជនសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

---

[10] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Popovic, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បង្ខំរបស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធមិនព្រមដោះលែង Ljumbomir Borovcanin ជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-05-88-AR65.2, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ មិថុនា ២០០៦, កថាខណ្ឌទី៨ [ចាប់ពីនេះតទៅហៅថា* សាលដីកាសម្រេចលើករណី Popovic] ។

[11] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Haradinaj, ដីកាសម្រេចលើញត្តិស្នើសុំដោះលែងជាបណ្តោះអាសន្នរបស់ Lahi Brahimaj, សំណុំរឿងលេខ IT-04-84-PT, របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី៣ ឧសភា ២០០៦, កថាខណ្ឌទី៦។*

(២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

៧. មូលហេតុទាំង៥ ដែលស្ថិតនៅក្រោមវិធាន៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង គឺមានលក្ខណៈដាច់ដោយឡែកៗពីគ្នា[12] ។ មិនតម្រូវឲ្យ សហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែរកឲ្យឃើញថា រាល់មូលហេតុនីមួយៗត្រូវបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវ នៅមុនពេលដែលខ្លួនត្រូវធ្វើការពិចារណាថា ការឃុំខ្លួនគឺជាវិធានការដ៏ចាំបាច់ ឬថា ការបន្តថិរវេលាត្រូវបានចេញដីកាសម្រេចរួចហើយនោះទេ។ ផ្ទុយទៅវិញ បើសិនជា សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំង៥នេះមានអត្ថិភាពនោះ គឺការធ្វើតេស្តសាកល្បងសម្រាប់ការឃុំខ្លួនត្រូវបានបំពេញគ្រប់តាមលក្ខខណ្ឌតម្រូវហើយ ។ វិធីសាស្ត្រនេះក៏ត្រូវបានតុលាការព្រហ្មទណ្ឌដទៃៗទៀត អនុវត្តតាមក្នុងការដោះស្រាយលើករណីរឿងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នានេះដែរ[13] ។

## *ការអនុវត្តន៍ឆន្ទានុសិទ្ធនៅក្នុងការពិនិត្យពិចារណាលើការឃុំខ្លួន*

៨. អង្គជំនុំជម្រះមួយរបស់តុលាការ មានឆន្ទានុសិទ្ធិលើវិធីសាស្ត្រក្នុងការធ្វើសេចក្តីសន្និដ្ឋានបែប

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១២១ ។

[13] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sainovic ហើយនិង Odjanic,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការបដិសេធលើសំណើសុំអនុញ្ញាតប្តឹងឧទ្ធរណ៍របស់ Odjanic, សំណុំរឿងលេខ IT-99-37-AR65.2, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ មិថុនា ២០០៣, ទំព័រ៣, ERN 00154039-42 , និងដែលត្រូវបានអនុម័តយកតាមដោយ អង្គបុរេជំនុំជម្រះ នៃ អ.វ.ត.ក ។ *ករណីរឿងរបស់សហព្រះរាជអាជ្ញា ទល់នឹង កាំង ហ្កេកអ៊ាវ ហៅ "**ឌុច**",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ *កាំង ហ្កេកអ៊ាវ ហៅ "**ឌុច**",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១), ចុះថ្ងៃទី៣ ធ្នូ ២០០៧, ERN 00154284-00154302, C5/45, កថាខណ្ឌទី៥៩ [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន **ឌុច**]។

ណាមួយអំពីថា ការឃុំខ្លួនគឺជាវិធានការដ៏ចាំបាច់ ឬថា ការបន្តថិរវេលាត្រូវបានចេញដីការួចហើយ ។ ឆន្ទានុសិទ្ធិបែបនេះជាធម្មតាត្រូវបានអនុវត្តដោយត្រូវយកចិត្តទុកដាក់ទៅលើរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង និងទៅលើរាល់អង្គហេតុពាក់ព័ន្ធទាំងអស់នៃករណីរឿងដែលរួមមាន៖ ស្ថានទម្ងន់នៃបទចោទប្រកាន់, ហេតុផលសមស្របដែលធ្វើឱ្យជឿជាក់, ចរិតនិងអាកប្បកិរិយាពីអតីតកាល និងបច្ចុប្បន្នរបស់ចុងចោទ ផលប្រយោជន៍របស់សាក្សីនិងជនរងគ្រោះ និងផលប្រយោជន៍សម្រាប់យុត្តិធម៌ទាំងមូល[14] ។ ការណ៍នេះគឺវាស្របទៅតាមទម្លាប់អនុវត្តដែលត្រូវបានទទួលយល់ព្រមនៅក្នុង តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតដែលតុលាការនេះបានអនុម័តយកតាម[15] ។

## *ការបន្តថិរវេលានៃការឃុំខ្លួន*

៩. វិធាន ៦៣(៦) បានចែងអំពីការពិនិត្យឡើងវិញជាស្វ័យប្រវត្តិដោយកំណត់ពេលទៀងទាត់ នូវការឃុំខ្លួនចុងចោទណាម្នាក់ ។ បញ្ញត្តិបែបដូចនេះ គឺមិនមាននៅក្នុងឯកសារមូលដ្ឋាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (“ICTY”) និងប្រទេសរ្វ៉ាន់ដា (“ICTR”) ព្រមទាំងនៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (“SCSL”) ។ ទោះជាយ៉ាងនេះក៏ដោយ ក៏តុលាការ*ពិសេស* ទាំងនោះ (*ad hoc* tribunals) បានរក្សាទុកចំពោះពាក្យសុំដោះលែងថ្មីដែលទទួលបានជោគជ័យថា ចុងចោទត្រូវតែបង្ហាញអំពី “ការផ្លាស់ប្តូរកាលៈទេសៈដ៏សំខាន់”[16]។

១០. ស្រដៀងគ្នាទៅនឹងវិធានសម្រាប់អង្គជំនុំជម្រះនេះដែរ វិធាន ១១៨ នៃវិធាននីតិវិធី និងភស្តុតាង

---

[14] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Ljube Boskoski និង Johan Talukovski,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្តរបស់ Johan Tlukovski ស្តីពីការដោះលែងជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ កក្កដា ២០០៧, កថាខណ្ឌទី៤, ERN 00153946-54 ។

[15] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន ឌុច, កថាខណ្ឌទី២៧ ។

[16] *រដ្ឋអាជ្ញា ទល់នឹង Boskoski និង Tarculovski,* សំណុំរឿងលេខ IT-04-82-PT, សេចក្តីសម្រេចពាក់ព័ន្ធនឹងញត្តិដែលបានពិនិត្យឡើងវិញដើម្បីធ្វើការដោះលែង Tarculovski ជាបណ្តោះអាសន្ន, ចុះថ្ងៃទី១៧ មករា ២០០៧, ទំព័រទី ៩ ។

របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) តម្រូវថាការឃុំខ្លួនមុនពេលជំនុំជម្រះលើចុងចោទណាម្នាក់ ត្រូវតែបានពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះរបស់ខ្លួន យ៉ាងហោចណាស់ រៀងរាល់ ១២០ថ្ងៃម្តង ។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC មាន “កាតព្វកិច្ចផ្សេង និងឯករាជ្យ [...] ដើម្បីធានាថា បុគ្គលម្នាក់មិនត្រូវបានគេឃុំខ្លួនក្នុងថិរវេលាមួយដែលមិនសមហេតុផលនៅមុនពេលជំនុំជម្រះក្តីទេ”[17] ។ អង្គបុរេជំនុំជម្រះ អាចកែប្រែសេចក្តីសម្រេចរបស់ខ្លួន ស្តីពីការឃុំខ្លួនបាន “បើខ្លួនយល់ឃើញថាការផ្លាស់ប្តូរកាលៈទេសៈតម្រូវឲ្យធ្វើយ៉ាងដូច្នោះ”[18] ។ នៅតុលាការ ICC “អយ្យការត្រូវទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងអត្ថិភាពបន្ត នៃលក្ខខណ្ឌនានា [...] នៅមុនពេលជំនុំជម្រះក្តី”[19] ។

១១. នៅចំពោះមុខអង្គជំនុំជម្រះនេះ វិធានមិនបានផ្តល់អំណាចឲ្យដល់សហព្រះរាជអាជ្ញា ឬភាគីណាមួយឡើយ ក្នុងការកំណត់អំពីការពន្យារពេលនៃការឃុំខ្លួនមុនពេលជំនុំជម្រះ[20] ។ វិធានគ្រាន់តែបានចែងអំពីការប្តឹងតវ៉ាដែលជនជាប់ឃុំត្រូវដាក់ ដែលក្រោយមក មានការគាំទ្រដល់តម្រូវការនៃដីកាបង្គាប់សមស្របណាមួយ[21] ។

### *ការពន្យារពេលដ៏សមស្រប*

១២. នៅក្នុងដីកាសម្រេចបន្តការឃុំខ្លួន សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថា ការកន្លងផុតទៅ

---

[17] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួន Germaine Katanga មុនពេលជំនុំជម្រះក្តី, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី០៩ កក្កដា ២០០៨, ទំព័រទី ៤ ។

[18] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញនូវសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃការឃុំខ្លួន Germaine Katanga មុនពេលជំនុំជម្រះក្តី, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី០៨ សីហា ២០០៨, ទំព័រទី ៦ ។

[19] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួន Germaine Katanga មុនពេលជំនុំជម្រះក្តី, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី០៩ កក្កដា ២០០៨, ទំព័រទី ៤ ។

[20] វិធានផ្ទៃក្នុង, វិធាន ៦៣(៧) ។

[21] វិធានផ្ទៃក្នុង, វិធាន ៦៣(៧) ។

នៃពេលវេលាគឺទាក់ទងទៅនឹងការកំណត់ថា តើមូលដ្ឋាននៃការឃុំខ្លួនបណ្ដោះអាសន្នដែលបាន បន្តកំពុងតែនៅមាន ឬមួយយ៉ាងណា[22] ។ នៅពេលដែលថិរវេលាត្រូវបានតុលាការអន្តរជាតិ នានាយកចិត្តទុកដាក់ពិចារណាថាជាកត្តាពាក់ព័ន្ធមួយ នៅក្នុងការកំណត់ពីភាពស្របច្បាប់នៃ ការឃុំខ្លួន មេធាវីការពារក្ដីមិនបានបង្ហាញថា តើការឃុំខ្លួនក្នុងរយៈពេលមួយឆ្នាំនោះ បានធ្វើ ឱ្យខូចខាតទៅលើសំណុំរឿងរបស់ដើមបណ្ដឹងឧទ្ធរណ៍តាមរបៀបណា ដើម្បីការពារដល់ការ ជំនុំជម្រះក្ដីប្រកបដោយភាពយុត្តិធម៌ និង/ឬ ដើម្បីបង្ហាញថាតើវាអាចផ្ដល់យុត្តិកម្មលើការ ពិចារណាឡើងវិញអំពីការឃុំខ្លួន បានតាមរបៀបណានោះទេ ។

១៣. មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងថា "ក្នុងករណីនៃការសម្រេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនគ្រប់រូបមានសិទ្ធិក្នុងការទទួលបាន នូវ [...] ការជំនុំជម្រះក្ដីដោយឥតពន្យារពេលយូរ" ។ មាត្រា ៩(៣) នៃ ICCPR, មាត្រា ៧(៥) នៃអនុសញ្ញាស្ដីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអាមេរិក និងមាត្រា ៥(៣) នៃអនុសញ្ញាស្ដីពី សិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប បានចែងថា ជនគ្រប់រូបដែលត្រូវបានឃុំខ្លួន មានសិទ្ធិក្នុងការ ទទួលបាននូវការជំនុំជម្រះក្ដីក្នុង "រយៈពេលមួយដ៏សមស្រប" ។ គណៈកម្មាធិការផ្នែកសិទ្ធិ មនុស្សធ្លាប់បានសម្រេចថា "អ្វីដែលបង្កើតបានជា "រយៈពេលមួយដ៏សមស្រប" គឺជាបញ្ហានៃ ការវាយតម្លៃលើករណីជាក់លាក់នីមួយៗ"[23] ។ នេះគឺជាគោលការណ៍ដែលគេបានបកស្រាយ លើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានយល់ព្រមដោយតុលាការពិសេសសម្រាប់អតីត ប្រទេសយូហ្គោស្លាវី និងប្រទេសរ្វ៉ាន់ដា[24] ។

១៤. តុលាការ ICTY បានបង្កើតរឿងដូចនេះដើម្បីធ្វើឱ្យមានលក្ខណៈសមស្របនៃរយៈពេលឃុំ

[22] ដីកាសម្រេចបន្តការឃុំខ្លួន, C20/4, កថាខណ្ឌទី ៣៧ ។

[23] គណៈកម្មធិការសិទ្ធិមនុស្សរបស់ អសប, សេចក្ដីជូនដំណឹងលេខ ៣៣៦/១៩៨៨, ករណី N. Fillastre ទល់នឹង ប្រទេសបូលីវី (ទស្សនៈត្រូវបានអនុម័តនៅថ្ងៃទី០៥ វិច្ឆិកា ១៩៩១), មាននៅក្នុងឯកសាររបស់ អសប GAOR A/47/40 ។

[24] *រដ្ឋអាជ្ញា ទល់នឹង Kanyabashi,* សេចក្ដីសម្រេចលើញត្តិរបស់មេធាវី ស្នើសុំដោះលែងជនជាប់ចោទជាបណ្ដោះអាសន្ន, ចុះថ្ងៃទី២១ កុម្ភៈ ២០០១, កថាខណ្ឌទី ១១ ។ *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្ដីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែង បណ្ដោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។

ខ្លួនបណ្តោះអាសន្ន ដែលខ្លួនចាំបាច់ត្រូវវាយតម្លៃលើកាលៈទេសៈនៃករណីនីមួយៗ ដោយមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក. រយៈពេលនៃការឃុំខ្លួនដែលមានប្រសិទ្ធភាព,

ខ. រយៈពេលនៃការឃុំខ្លួនដែលពាក់ព័ន្ធទៅនឹងប្រភេទនៃបទឧក្រិដ្ឋ

គ. ផលវិបាកតាមផ្លូវកាយ និងផ្លូវចិត្ត នៃការឃុំខ្លួនលើជនជាប់ឃុំ

ឃ. ភាពស្មុគ្រស្មាញនៃសំណុំរឿង និងការស៊ើបអង្កេត

ង. ការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធីទាំងមូល[25] ។

១៥. តុលាការ ICTR បានអនុម័តលើការសាកល្បងស្រដៀងគ្នាមួយ នៅក្នុងការវាយតម្លៃលើភាពសមស្របនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយដោយមានកាលៈទេសៈនៃសំណុំរឿងនានានៅចំពោះមុខខ្លួន គឺនៅមិនទាន់ដែលបានរកឃើញនូវរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នណាមួយដែលមិនសមស្របនៅឡើយទេ[26] ។

១៦. ទោះបីជា បទចោទប្រកាន់នានាដែលបានធ្វើដោយ អ.វ.ត.ក មានភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏វិធាន ៦៣ បានចែងអំពីកិច្ចការពារមួយចំនួនដើម្បីធានាថា ការឃុំខ្លួនបណ្តោះអាសន្នគឺត្រូវមាន រយៈពេលខ្លីតាមដែលអាចធ្វើទៅបាន ។ វិធាន ៦៣(៦) និង ៦៣(៧) បានចែងថាគ្មានជនជាប់ចោទណាម្នាក់នៅចំពោះមុខ អ.វ.ត.ក អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នជាសរុប លើសពី ៣ (បី) ឆ្នាំបានទេ។ កិច្ចការពារទាំងនេះ មិនមាននៅចំពោះមុខតុលាការ

[25] *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-94-14-, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។

[26]ជាឧទាហរណ៍ សូមអាន៖ *រដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu, Justin Mugenzi, Jérome-Clément Bicamumpaka and Prosper Mugiraneze*, សេចក្តីសម្រេចលើពាក្យសុំរបស់ *Prosper Mugiraneze* ស្នើឱ្យបើកសវនាការ ឬបើមិនដូច្នោះទេសុំឱ្យមានដំណោះស្រាយលើសំណើបដិសេធរបស់ខ្លួន ដោយសារមានការបំពានលើសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវកាត់សេចក្តីមួយដែលគ្មានការពន្យារពេលមិនសមស្រប, សំណុំរឿងលេខ ICTR-99-50, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០៣ វិច្ឆិកា ២០០៤, កថាខណ្ឌទី ២៦ ។

ICTR និង ICTY ទេ ។ លើសពីនេះ ដូចដែលបានលើកឡើងខាងលើ វិធាន ៦៣(៦) និង ៦៣(៧) បានចែងអំពីការពន្យារពេលនៃការបន្តការឃុំខ្លួនជនត្រូវចោទ ជាស្វ័យប្រវត្តិ និងដោយទៀងទាត់ (យ៉ាងហោចណាស់មួយឆ្នាំម្តង) ។ ហេតុដូច្នេះ វិធានផ្ទៃក្នុងបានប្រមើលមើលយ៉ាងច្បាស់ថា គ្មានជនត្រូវចោទណាម្នាក់នឹងត្រូវឋិតនៅ ក្រោមការឃុំខ្លួនបណ្តោះអាសន្នដោយមានរយៈពេលមិនសមស្របនោះទេ ។

## ៤. អង្គហេតុ និង សេចក្តីសំអាង

### ក. បណ្តឹងឧទ្ធរណ៍ មិនកំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរកាលៈទេសៈដ៏សំខាន់ ដើម្បីធ្វើយុត្តិកម្មឲ្យមានការពិចារណាឡើងវិញអំពីការឃុំខ្លួននោះទេ

១៧. ដើមបណ្តឹងឧទ្ធរណ៍មិនបានកំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរដ៏សំខាន់ណាមួយ ដែលចាំបាច់ត្រូវធ្វើការពិចារណាអំពីការឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ឡើងវិញ ឬការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌនៃការឃុំខ្លួនទេ ។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចមួយដោយមានសំអាងហេតុគាំទ្រដល់ភាពចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន។ ដើមបណ្តឹងឧទ្ធរណ៍ជំទាស់ថា ពេលវេលាកន្លងផុតទៅចាប់តាំងពីពេលដែលមានការឃុំខ្លួនរបស់គាត់ ដោយមិនមាន “ការយកចិត្តទុកដាក់ហ្មត់ចត់” នៅពេលបើកធ្វើការស៊ើបសួរនោះ បញ្ជាក់ថាជាការត្រឹមត្រូវគឺត្រូវធ្វើការដោះលែងគាត់។

១៨. រយៈពេលនៃការឃុំខ្លួនត្រូវបានតុលាការអន្តរជាតិនានា ធ្វើការពិចារណាថាជាកត្តាពាក់ព័ន្ធ[27]។ ផ្ទុយទៅវិញ ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញឲ្យឃើញថា តើរយៈពេលនៃការឃុំខ្លួននោះបានធ្វើឲ្យខូចខាតលើសំណុំរឿងរបស់គាត់យ៉ាងណានោះទេ ដើម្បីការពារដល់ការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និង/ឬ ដើម្បីបង្ហាញថាតើវាអាចផ្តល់យុត្តិកម្មលើការពិចារណាឡើងវិញអំពីការឃុំខ្លួនបានតាមរបៀបណានោះទេ។ ដោយផ្អែកទៅលើកាលៈទេសៈនានានៃ

[27] ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញនូវសេចក្តីសម្រេចលើពាក្យសុំដោះលែង Mathieu Ngudjolo Chui ជាបណ្តោះអាសន្ន, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះនៃតុលាការ ICC, ចុះថ្ងៃទី២៣ កក្កដា ២០០៨, ទំព័រទី ១២ ។

រឿងក្តីនិងយុត្តិសាស្ត្រអន្តរជាតិរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ដើមបណ្តឹងឧទ្ធរណ៍ គឺស្របតាមមាត្រា៩(៣) នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ជនត្រូវចោទត្រូវបានដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន សម្រាប់រយៈពេលដ៏សមស្របមួយ ដោយសារតែមានការចោទប្រកាន់អំពីបទឧក្រិដ្ឋធ្ងន់ធ្ងរ, លក្ខណៈស្មុគ្រស្មាញនៃរឿងក្តី និងកម្រិតនៃការស៊ើបសួរដែលកំពុងតែអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។ ការថែរក្សាការពារផ្សេងៗដែលមាននៅក្នុងវិធានផ្ទៃក្នុងបានចែងអំពី ការកម្រិតទៅលើរយៈពេលនៃការឃុំខ្លួនអាចអនុញ្ញាតឱ្យធ្វើបាន និងចែងអំពីការពិនិត្យឡើងវិញលើការឃុំខ្លួនបណ្តោះអាសន្ន ដែលធ្វើឱ្យលែងមានការព្រួយបារម្ភអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលនឹងត្រូវអនុញ្ញាត ដើម្បីក្លាយទៅជាភាពមិនសមស្រប ។ ដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍។

### ខ. មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលបានចោទប្រកាន់ - វិធាន ៦៣(៣)(ក)

១៩. ដើមបណ្តឹងឧទ្ធរណ៍ជំទាស់ថា ដោយសារមានភស្តុតាងថ្មីៗជាច្រើនមិនទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង អ្នកសង្កេតការណ៍សត្យានុម័តម្នាក់មិនអាចសន្និដ្ឋានបានថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋនានាដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ[28] ។

២០. នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅក្នុងសេចក្តីសម្រេចស្តីពីការបន្តថិរវេលានៃការ ឃុំខ្លួនសហចៅក្រមស៊ើបអង្កេត បានធ្វើការកត់សម្គាល់ថា មូលហេតុដែលត្រូវបានរកឃើញ យ៉ាងច្បាស់នោះ មានអត្ថិភាពជាបន្តនៅឡើយ ដែលធ្វើឱ្យពួកខ្លួនជឿជាក់ថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេត បានរំលឹកថា អង្គបុរេជំនុំជម្រះ បានទទួលធ្វើការវិភាគមួយដ៏ពិស្តារ

---

[28] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ២១ ។

លើសំណុំរឿង ហើយបានរកឃើញថាមានភស្តុតាងគ្រប់គ្រាន់ ដើម្បីឲ្យអ្នកសង្កេតការណ៍សត្យានុម័តយល់ព្រមថា ដើមបណ្តឹងឧទ្ធរណ៍នោះ ធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ ។ សហចៅក្រមស៊ើបអង្កេត ក៏បានធ្វើការកត់សម្គាល់ផងដែរថា ការស៊ើបសួរបានដំណើរការទៅមុខ ចាប់តាំងពីមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មក ហើយថាលក្ខខណ្ឌនៃការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ នៅតែស្របទៅតាមវិធាន ៦៣(៣)(ខ) ជាបន្តទៅទៀត។ អាស្រ័យហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតបានបន្តការឃុំខ្លួនសម្រាប់រយៈពេលមួយដែលមានថិរវេលាមិនលើសពីមួយឆ្នាំ[29] ។

២១. នៅក្នុងការសម្រេចថាតើមាន ឬមិនមាន "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" អង្គបុរេជំនុំជម្រះ បានពិចារណាថាតើមានអង្គហេតុនានា ដែលអ្នកសង្កេតការណ៍សត្យានុម័តយល់ព្រមថា ភាគីប្តឹងឧទ្ធរណ៍នោះធ្លាប់បានប្រព្រឹត្តបទល្មើសនានាដែលបានចោទប្រកាន់[30] ។ គេបានកត់សម្គាល់ថាពាក្យ "បានប្រព្រឹត្ត" ត្រូវតែបានយល់ថា "ធ្វើឲ្យកើតមានឡើងនូវការទទួលខុសត្រូវជាបុគ្គល" ដែលរាប់បញ្ចូលទាំង រៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ ឬ ប្រព្រឹត្ត[ឧក្រិដ្ឋកម្ម] ព្រមទាំង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌកំរិតខ្ពស់[31] ។

២២. ភាគីប្តឹងឧទ្ធរណ៍ មិនជំទាស់ទៅនឹងការកំណត់លើ មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់ នៃសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននោះទេ ។ គាត់គ្រាន់តែជំទាស់ទៅនឹងកង្វះខាតក្នុងការយកចិត្តទុកដាក់ហ្មត់ចត់របស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ នៅក្នុងកិច្ចដំណើរការស៊ើបសួររបស់ពួកខ្លួន ហើយដោយសាររឿងនេះក៏បានអះអាងថាសិទ្ធិជាមូលដ្ឋានរបស់ខ្លួនមិនត្រូវបានគេគោរពទេ[32] ។ គាត់អះអាងថា ការដោះលែងជាបណ្តោះអាសន្ន គឺជាដំណោះស្រាយមិនចំពោះមួយ[33] ។

---

[29] ដីកាសម្រេចបន្តថិរវេលា, ទំព័រ ១១ ។

[30] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ៧១ ។

[31] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ៧១ ។

[32] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៨ ។

[33] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១២ ។

២៣. ដូចដែលបានថ្លែងនៅខាងលើស្រាប់ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីបណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួន អង្គបុរេជំនុំជម្រះ បានរកឃើញថា អ្នកសង្កេតការណ៍សត្យានុម័តមុខជានឹងយល់ព្រម តាមឯកសារនៅក្នុងសំណុំរឿងនោះថា ភាគីប្តឹងឧទ្ធរណ៍ត្រូវមានការទទួលខុសត្រូវលើ ឬធ្លាប់បានប្រព្រឹត្តនូវបទឧក្រិដ្ឋ ដែលមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះ[34] ។ ការកំណត់នេះមានមូលដ្ឋានលើភស្តុតាង នៅក្នុងសំណុំរឿងដាក់បន្ទុកទៅលើភាគីប្តឹងឧទ្ធណ៍ ដែលមានកាន់តែច្រើនឡើងទាំងចំនួន និងភាពធ្ងន់ធ្ងរ នៅក្នុងប៉ុន្មានខែថ្មីៗនេះ។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសយ៉ាងហោចណាស់ក៏ដប់ពីរ(១២)ដែរ នៅក្នុងសំណុំរឿងលេខ ០០២ (ឯកសារលេខ D25, D40, D43, D78, D82, D91, D92, D93, D94, D104, D107, និង D115)[35] ហើយសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេតរបស់ខ្លួន បានសម្ភាសន៍សាក្សីចំនួនជាងមួយរយនាក់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែល ជនទាំងប្រាំរូប ត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ដែលក្នុងនោះរួមមានដើមបណ្តឹងឧទ្ធរណ៍ផង អាចបានប្រព្រឹត្ត។ បន្ថែមពីលើនេះទៀត ចំណុចសំខាន់ដែលមាននៅក្នុងសំណុំរឿងលេខ ០០១ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងរឿងក្តីរបស់ដើមបណ្តឹងឧទ្ធរណ៍ ត្រូវបានផ្ទេរទៅក្នុងសំណុំរឿងលេខ ០០២ រួចហើយ ដោយ

---

[34] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ៩៤ ។

[35] ក្នុងចំណោមដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងនោះ មានដីកាចំនួន៧ ទាក់ទងទៅនឹងការធ្វសម្ភាសន៍សាក្សី: ឯកសារលេខ D25 (ការធ្វើសម្ភាសន៍សាក្សី៣៦នាក់), ឯកសារលេខ D40 (ការធ្វើសម្ភាសន៍សាក្សី២៥នាក់), ឯកសារលេខ D91 (ការធ្វើសម្ភាសន៍សាក្សី២៤នាក់), ឯកសារលេខ D92 (ការធ្វើសម្ភាសន៍សាក្សី៨នាក់), ឯកសារលេខ D94 (ការធ្វើសម្ភាសន៍សាក្សី១៦នាក់), ឯកសារលេខ D107 (ការធ្វើសម្ភាសន៍សាក្សី១នាក់យ៉ាងតិច) និង ឯកសារលេខ D115 (ការធ្វើសម្ភាសន៍ Laurence PICQ) ដែលមានចំនួនសរុបយ៉ាងតិច ១១៥នាក់ ដែលបានដាក់នៅក្នុងសំណុំរឿង។ ក៏ប៉ុន្តែ តាមសហចៅក្រមស៊ើបអង្កេត មានដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនដែលកំពុងតែត្រូវបានអនុវត្ត។ គឺមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដោយសារតាមធម្មតាភាគីនានាត្រូវបានគេផ្តល់ពត៌មាន-តែជាអកុសល-ត្រូវបានគេផ្តល់ពត៌មានអំពីដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងនោះ នៅពេលដែលដីកាទាំងនោះត្រូវបានអនុវត្តចប់សព្វគ្រប់រួចទៅហើយ។ គឺបានន័យថា តាមការពិត មានភវនីយភាពយ៉ាងខ្ពស់ថា មានចម្លើយច្រើនជានេះឆ្ងាយណាស់ដែលសហចៅក្រមស៊ើបអង្កេតប្រមូលបាន ចាប់តាំងពីបទសម្ភាសន៍សាក្សីទាំង១១៥នេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចមក។ សហព្រះរាជអាជ្ញាសូមជំរុញលើកទឹកដល់ការអនុវត្តក្នុងការដាក់ចម្លើយសាក្សីភ្លាមៗតាមដែលអាចធ្វើទៅបាននៅក្នុងសំណុំរឿង នៅមុនពេលដែលរបាយការណ៍ស្តីពីការអនុវត្តដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានចប់សព្វគ្រប់។

កំណត់មួយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៨[36]។ កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំនួន២៨ ដែលបានធ្វើឡើងក្នុងបរិបទនៃសំណុំរឿងលេខ ០០១ ត្រូវបានសហចៅក្រមស៊ើបអង្កេតដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ រួចហើយ[37]។ លើសពីនេះមានកំណត់ហេតុសម្ភាសន៍ ឌុច ចំនួនដប់(១០) ដែលទាក់ទងផ្ទាល់ទៅនឹងនាទីរបស់ជនត្រូវចោទបួនរូបផ្សេងទៀត ដែលក្នុងនោះរួមមាន ដើមបណ្តឹងឧទ្ធរណ៍ផងត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតកាលពីចន្លោះខែមិថុនា និងខែវិច្ឆិកា ឆ្នាំ២០០៨ ក្នុងបរិបទជាក់លាក់នៃសំណុំរឿងលេខ០០២[38]។

២៤. សាក្សីនានាបាននិយាយថា ភាគីប្តឹងឧទ្ធរណ៍មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗ ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍ភស្តុតាងនៅក្នុងសំណុំរឿង ក៏ដូចជាត្រូវបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្តីពីបណ្តឹងឧទ្ធរណ៍ លើការឃុំខ្លួនដែរ បានគាំទ្រដល់ មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ភាគីប្តឹងឧទ្ធរណ៍ គឺជាផ្នែកមួយនៃរចនាសម្ព័ន្ធបញ្ជាជាន់ខ្ពស់របស់ខ្មែរក្រហម[39] ។ សាក្សីម្នាក់ ធ្លាប់បានឃើញភាគីប្តឹងឧទ្ធរណ៍ ចូលរួមនៅក្នុងការប្រជុំប្រចាំសប្តាហ៍មួយនៅ

---

36 *ករណីរឿងរបស់ នួន ជា និងជនដទៃទៀត*, កំណត់សំគាល់ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ តុលា ២០០៨, ឯកសារលេខ D108, ERN 00236076-77 (ភាសាអង់គ្លេស) និង ឧបសម្ព័ន្ធភ្ជាប់នឹងកំណត់សំគាល់នេះ លេខ D108/1។

36 *ករណីរឿងរបស់ នួន ជា និងជនដទៃទៀត*, កំណត់សំគាល់ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣០ ឧសភា ២០០៨, ឯកសារលេខ D86, ERN 00194661-67 (ភាសាអង់គ្លេស) ។

37 *ករណីរឿងរបស់ នួន ជា និងជនដទៃទៀត*, កំណត់សំគាល់ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣០ ឧសភា ២០០៨, ឯកសារលេខ D86, ERN 00194661-67 (ភាសាអង់គ្លេស) ។

38 កំណត់ហេតុស្តាប់ចម្លើយមួយចំនួនដែលមានដាក់លេខយោងដូចខាងក្រោមនេះ: លេខ D87 (ថ្ងៃទី២ មិថុនា ២០០៨), លេខ D88 (ថ្ងៃទី២ មិថុនា ២០០៨), លេខ D91 (ថ្ងៃទី៣ មិថុនា ២០០៨ ), លេខ D89 (ថ្ងៃទី២៤ មិថុនា ២០០៨), ឯកសារលេខ D90 (ថ្ងៃទី២៥ មិថុនា ២០០៨), លេខ D95 (ថ្ងៃទី១៥ កក្កដា ២០០៨), លេខ D117 (ថ្ងៃទី១៩ វិច្ឆិកា ២០០៨), លេខ D118 (ថ្ងៃទី២០ វិច្ឆិកា ២០០៨), លេខ D119 (ថ្ងៃទី២៥ វិច្ឆិកា ២០០៨), លេខ D120 (ថ្ងៃទី២៧ វិច្ឆិកា ២០០៨), និង លេខ D121 (ថ្ងៃទី២៨ វិច្ឆិកា ២០០៨)។ កំណត់ហេតុស្តាប់ចម្លើយដទៃទៀត គ្រោងធ្វើនៅខែមករា និងខែកុម្ភៈ២០០៩ អាស្រ័យទៅលើលទ្ធភាពរបស់មេធាវីការពារក្តីអន្តរជាតិ។

39 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ៧៥-៨ ។

ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ការិយាល័យ ប-១ ជាមួយនិង នួន ជា, ប៉ុល ពត, សុន សេន, ឌុច, និង តាម៉ុក[40] ។ សាក្សីម្នាក់ទៀតធ្លាប់បាន ឃើញភាគីប្តឹងឧទ្ធរណ៍ ជាមួយនិង ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធ នៅក្នុងវគ្គប្រជុំរៀនសូត្រ នៅបូរីកីឡា និងស្តាតអូឡាំពិក ក្នុងរវាងឆ្នាំ ១៩៧៦ និង ១៩៧៧[41] ។ ថ្មីៗនេះ សាក្សីម្នាក់ឈ្មោះ ឡុង ពិក បានអះអាងលើសពីអ្វីៗទាំងអស់នៅក្នុងបទសម្ភាសន៍នានាដ៏ទូលំទូលាយថា ការដឹងឮដ៏ទូលំទូលាយរបស់ភាគីប្តឹងឧទ្ធរណ៍អំពីការបោសសម្អាត និងតួនាទីនៅក្នុងការបោសសម្អាតនៅក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ[42] ។

២៥. ភាគីប្តឹងឧទ្ធរណ៍ ក៏បាននិយាយផងដែរថា ទីមួយ "មានភស្តុតាងតិចតួចណាស់ដែលបានដាក់នៅក្នុងសំណុំរឿង" និងទីពីរ "ការស៊ើបសួរដែលក្រុមមេធាវីការពារក្តីដទៃទៀតបានស្នើសុំមិនត្រូវបានគេធ្វើតាមទេ"[43] ។ ការជំទាស់នេះ មិនត្រូវទៅតាមភាពពិតប្រាកដនៃភស្តុតាងដែលបានប្រមូលផ្តុំទុកនៅក្នុងសំណុំរឿងទេ ដែលបច្ចុប្បន្ននេះមានចំនួនជាង ៤៥០ សឺមី[44] និងសំណើសុំឱ្យមានការស៊ើបសួរ ដែលបច្ចុប្បន្ននេះកំពុងត្រូវបានសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណា[45] ។ នៅពេលដែលជនត្រូវចោទដទៃទៀត ធ្លាប់បានដាក់សំណើនានាសុំឱ្យមានការស៊ើបសួរ ភាគីប្តឹងឧទ្ធរណ៍បែរជាមិនបានដាក់ទេ ។ អាស្រ័យហេតុដូចនេះ ការជំទាស់របស់ភាគីប្តឹងឧទ្ធរណ៍អំពីថា "មិនមានការរីកចម្រើន" គឺគ្មានមូលដ្ឋានទេ ហើយគួរតែត្រូវបានច្រានចោល ។

២៦. មិនមានភស្តុតាងដោះបន្ទុកសំខាន់ៗ ត្រូវបានរកឃើញដើម្បីធ្វើឱ្យអន្តរាយដល់ការកំណត់បាន

---

[40] ចម្លើយរបស់សាក្សី (បានលុបចេញ) ។

[41] ចម្លើយរបស់សាក្សី (បានលុបចេញ)។

[42] ដីកាសម្រេចបន្តឋិរវេលា, កថាខណ្ឌទី ៤០ ។

[43] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១០ ។

[44] ករណីរឿងរបស់ នួន ជា - លិខិតពី សហចៅក្រមស៊ើបអង្កេត ផ្ញើជូនប្រធានមន្ទីរឃុំឃាំង, *ការចូលមើលសំណុំរឿងពីសំណាក់ជនត្រូវចោទ,* ឯកសារយោងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស/A228 & A239, ចុះថ្ងៃទី១១ ធ្នូ ២០០៨, ERN 00250695, A228/2 ។

[45] សហចៅក្រមស៊ើបអង្កេត, អនុស្សរណៈអន្តរការិយាល័យស្តីពីសំណើសុំការបំភ្លឺ, ចុះថ្ងៃទី២៦ វិច្ឆិកា ២០០៨, សំណុំរឿងលេខ ០០២ - នួន ជា, ចុះថ្ងៃទី១២ ធ្នូ ២០០៨, ERN 00250662, D100/5 ។

នូវ "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" នេះទេ ។ សព្វថ្ងៃនេះ ភាគីប្តឹងឧទ្ធរណ៍ មិនបានដាក់ឯកសារណាមួយបញ្ចូលទៅក្នុងសំណុំរឿងទេ សូម្បីតែឯកសារដោះបន្ទុក សម្រាប់ធ្វើឱ្យមានការពិចារណាជាថ្មីឡើងវិញនូវការកំណត់នោះ ក៏រឹតតែតិចណាស់ទៅទៀត ។

២៧. ភាគីប្តឹងឧទ្ធរណ៍ ក៏បានជំទាស់ផងដែរថា សហចៅក្រមស៊ើបអង្កេត កំពុងទុកឱ្យការប្រើប្រាស់នូវសិទ្ធិនៅស្ងៀមមិននិយាយស្តីរបស់គាត់ ប្រឆាំងនឹងរូបគាត់វិញ[46] ។ នេះមានមូលដ្ឋាននៅលើ ការយល់ខុសទៅលើដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន ។ សហចៅក្រមស៊ើបអង្កេត គ្រាន់តែបានអះអាងថាការប្រើប្រាស់នូវសិទ្ធិរបស់ភាគីប្តឹងឧទ្ធរណ៍ "គឺមិនមែនជាអំណោយផល ដល់ដំណើរការនីតិវិធីឱ្យបានឆាប់រហ័សនោះទេ"[47] ។ ការអះអាងនេះ មិនបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត បានទុកឱ្យការប្រើប្រាស់សិទ្ធិដោយភាគីប្តឹងឧទ្ធរណ៍ ដើម្បីប្រឆាំងនឹង រូបគាត់ទេ ។ សហព្រះរាជអាជ្ញា បញ្ជាក់ថា សិទ្ធិនៅស្ងៀមមិននិយាយស្តីរបស់ចុងចោទ ត្រូវបានការពារដោយច្បាប់ដែលកំពុងអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះនេះ និងនៅក្នុង ស្តង់ដារអន្តរជាតិមួយដែលភ្ជាប់កាតព្វកិច្ចទៅលើវា ។ ក្នុងឋានៈជាចៅក្រមអញ្ញត្រ៊ីត ដែលបានដំណើរការស្វែងរក នូវការពិត សហចៅក្រមស៊ើបអង្កេតត្រូវតែប្រមូលនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ។ ដោយការសន្មត ជនត្រូវចោទម្នាក់អាចនឹង -ប្រសើរជាងអ្នកដទៃទៀត- ជួយដល់សហចៅក្រមស៊ើបអង្កេត ក្នុងការស្វែងរកភស្តុតាងដោះបន្ទុក ។ បើមិនមានកិច្ចសហប្រតិបត្តិការនេះទេ ការស៊ើបសួរ ចាំបាច់ត្រូវតែ ប្រើប្រាស់នូវពេលវេលាយូរជាង ពេលវេលាដែលត្រូវប្រើប្រាស់នៅពេលដែលភាគីប្តឹងឧទ្ធរណ៍ បានបង្ហាញនូវភស្តុតាងនោះ ។

២៨. អាស្រ័យហេតុដូចនេះ សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ ច្រានចោលនូវសេចក្តីសំអាង របស់ភាគីប្តឹងឧទ្ធរណ៍ ដែលថា សិទ្ធិនៅស្ងៀមមិននិយាយស្តីរបស់ខ្លួន ត្រូវបានសហ

[46] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១១ ។

[47] ដីកាសម្រេចបន្តថិរវេលា, កថាខណ្ឌទី ៤១ ។

ចៅក្រមស៊ើបអង្កេត កំពុងប្រើប្រាស់ដើម្បីប្រឆាំងនឹងរូបគាត់ ។ សហព្រះរាជអាជ្ញា ក៏ស្នើផង ដែរឲ្យ អង្គបុរេជំនុំជម្រះ ចាត់ទុកថា មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់ នៅតែមាន អត្ថិភាពជាបន្តទៀត ដែលថា ភាគីប្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដែលបាន បញ្ជាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។

**គ. ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ - វិធាន ៦៣(៣)(ខ)**

២៩. ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញអត្ថសញ្ញាណនូវការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណា មួយដើម្បីបង្ហាញឲ្យឃើញថា លក្ខខណ្ឌនានានៅក្រោមវិធាន ៦៣(៣)(ខ) ដែលជាការចាំបាច់ សម្រាប់ការឃុំខ្លួនគាត់នោះមិនបានបំពេញនោះឡើយ ។ ការកំណត់សម្រេចរបស់អង្គបុរេជំនុំ-ជម្រះនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ដែលថា ការឃុំខ្លួនបណ្តោះអាសន្ននៅមន្ទីរឃុំឃាំង អ.វ.ត.ក គឺជាការចាំបាច់ ដែលបានប្រកាសបន្ទាប់ពីមានការពិនិត្យឡើងវិញលើ ភស្តុតាង នានាទាំងអស់នៅក្នុងសំណុំរឿងនាថ្ងៃខែឆ្នាំនោះ ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ភស្តុតាង ថ្មីណាមួយទេចាប់តាំងពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ មក ដែលអាចនឹងនាំឲ្យអង្គបុរេជំនុំ ជម្រះផ្លាស់ប្តូរការសម្រេចរបស់ខ្លួន ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា (១) គម្រោងសង្ខេប ប្រកបដោយសនិទានភាពនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន បណ្តោះអាសន្ន គឺនៅតែមានសុពលភាពរហូតដល់សព្វថ្ងៃនេះ និងគួរតែត្រូវបានលើកកម្ពស់ និង (២) ការឃុំខ្លួនក្នុងផ្ទះ - ដូចដែលបណ្តឹងឧទ្ធរណ៍នេះបានស្វែងរក - ក៏មិនមែនជាជម្រើស ផ្សេងសម្រាប់ការឃុំខ្លួនដែលមានលក្ខណៈស្ថិតស្ថេរ នៅមន្ទីរឃុំឃាំង អ.វ.ត.ក ហើយក៏មិន មែនដើម្បីការពារវត្ថុបំណងនៃវិធាន៦៣(៣)(ខ) នោះដែរ ។

៣០. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គបុរេជំនុំជម្រះសម្រេចថា លក្ខខណ្ឌនានា នៃការឃុំខ្លួន ដូចមានចែងនៅក្រោមវិធាន៦៣(៣)(ខ)(៣-៤) ត្រូវបាន និងនៅតែបន្តបំពេញ បានតាមលក្ខខណ្ឌទាំងអស់នោះ ដើម្បីជាយុត្តិកម្មក្នុងការពន្យារពេលនៃការឃុំខ្លួនបណ្តោះ អាសន្ន លើដើមបណ្តឹងឧទ្ធរណ៍ ។

## ឃ. គ្មានទម្រង់ករណ៍ត្រូវបានធ្វើឡើងសម្រាប់ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និង ការឃុំខ្លួនក្នុងផ្ទះទេ

៣១. វិធានមិនបានចែងឲ្យមានទម្រង់ផ្សេងសម្រាប់ការឃុំខ្លួននោះទេ[48] ។ ប៉ុន្តែ វិធាន៦៥(១) រំពឹងទុកថា ចុងចោទអាចនឹងត្រូវបានដោះលែងពីមន្ទីរឃុំឃាំង តាមដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ នៅក្រោមលក្ខខណ្ឌនានាចាំបាច់ដើម្បីធានាវត្តមានរបស់គាត់នៅក្នុងអម្លុងពេលនៃកិច្ចដំណើរការនីតិវិធី និងដើម្បីការពារអ្នកដទៃទៀត[49] ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌនានាដែលចាំបាច់សម្រាប់ការឃុំឃាំងនៅក្រោមវិធាន៦៣(៣)(ខ) ត្រូវបានបំពេញនោះ ចុងចោទមិនអាចត្រូវបានដោះលែងតាមការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[50] ។

៣២. ទោះបីជាចុងចោទត្រូវបានដាក់ឲ្យជាប់ឃុំក្នុងផ្ទះ ឬ “ឃុំខ្លួនក្នុងមន្ទីរពេទ្យ” ក៏ដោយ ក៏វាអាចមានហានិយភ័យយ៉ាងខ្ពស់ ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ដែរ ។ គាត់នឹងតម្រូវឲ្យមកកាន់បរិវេណអ.វ.ត.ក ទៅតាមកាលៈទេសៈខុសៗគ្នា ហើយវានឹងមានការលំបាកដើម្បីធានាចំពោះសុវត្ថិភាពរបស់គាត់ ក្នុងពេលដឹកជញ្ជូនចេញពីមន្ទីរពេទ្យ ឬពីផ្ទះរបស់គាត់ មកកាន់ អ.វ.ត.ក ដើម្បីចូលរួមផ្ទាល់នៅក្នុងសវនាការសាធារណៈផ្សេងៗ[51] ។ មន្ទីរឃុំឃាំង អ.វ.ត.ក “ត្រូវបានបំពាក់ឧបករណ៍យ៉ាងត្រឹមត្រូវ ដើម្បីផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ទៅតាមការចាំបាច់”[52] ។

៣៣. ច្បាប់លក្ខន្តិកៈ ឬវិធានស្តីពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានាមិនបានចែងឲ្យមាន “ការឃុំខ្លួនក្នុងផ្ទះ” ទេ ។ គ្រប់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់ មានតែ ICTY មួយគត់ ដែលបានពិចារណាទៅលើសំណើបែបនេះ តែនៅក្នុងកាលៈទេសៈដ៏កម្រ ។ ក្នុងករណីរបស់

---

[48] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១១៩ ។

[49] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១២០ ។

[50] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១២១ ។

[51] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១២២ ។

[52] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី១២៣ ។

*Blaskic,* តុលាការបានអនុញ្ញាតតាមសំណើដែលស្នើសុំឱ្យមាន ការឃុំខ្លួនក្នុងផ្ទះមួយដែលមានសុវត្ថិភាព ដោយឈរលើមូលហេតុថា ជនជាប់ចោទបានបំពេញទៅតាមបុរេលក្ខខណ្ឌនានា សម្រាប់ការដោះលែងបណ្ដោះអាសន្ន ដែលគាត់បានចូលខ្លួនមកកាន់តុលាការដោយស្ម័គ្រចិត្តនៅពេលមួយដែលប្រទេសរបស់គាត់ (ក្រូអាត) មិនអាចចាប់ខ្លួនគាត់ដោយស្របច្បាប់ ឬមិនអាចធ្វើបត្យាប័នគាត់បាន និងថា គាត់បានស្ម័គ្រចិត្តយល់ព្រមលើការចំណាយទាំងអស់ដែលកើតចេញពីការឃុំខ្លួនរបស់គាត់ នៅក្នុងផ្ទះសុវត្ថិភាពនោះ[53] ។ ជាការគួរឱ្យកត់សម្គាល់លិខិតុបករណ៍មូលដ្ឋានរបស់ ICTY គឺមិនអនុញ្ញាតឱ្យជនជាប់ចោទត្រូវដាក់ឱ្យជាប់ឃុំឃាំងនៅក្នុងកន្លែងស្នាក់អាស្រ័យជាឯកជនណាមួយក្រោមការត្រួតត្រាតែម្នាក់គាត់នោះឡើយ[54] ។

៣៤. នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានធ្វើការសាកសួរដើមបណ្ដឹងឧទ្ធរណ៍ទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួនរូបគាត់ ។ នៅក្នុងពេលសាកសួរនេះ គាត់មិនបានត្អូញត្អែរអំពីធាតុជាសារវ័ន្តណាមួយនៃការឃុំខ្លួនគាត់នៅមន្ទីរឃុំឃាំង អ.វ.ត.ក ទេ[55] ។

៣៥. សហព្រះរាជអាជ្ញាសន្និដ្ឋានថា លក្ខខណ្ឌនានាដែលតម្រូវសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ននៅមន្ទីរឃុំឃាំង អ.វ.ត.ក នៅតែបានបំពេញទៅតាមលក្ខខណ្ឌ ។ ហេតុដូចនេះ ការស្នើសុំឱ្យមានការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមទម្រង់នៃ"ការឃុំខ្លួនក្នុងផ្ទះ" ឬ នៅក្រោមលក្ខខណ្ឌណាផ្សេងនោះ គួរតែត្រូវបានបដិសេធចោល ។

## ង. ការយកចិត្តទុកដាក់ ឬភាពខ្វះខាតការយកចិត្តទុកដាក់ គឺមិនពាក់ព័ន្ធទេ ចំពោះការកំណត់សម្រេចនេះ

---

[53] *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ដែលបានដាក់ស្របតាមវិធាន ៦៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង, សំណុំរឿងលេខ: IT-94-14-T, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៦, កថាខណ្ឌទី១៣-២៤ ។

[54] *រដ្ឋអាជ្ញា ទល់នឹង Ljubicic,* សេចក្តីសម្រេចលើសំណើសុំឱ្យមានការកែសម្រួលលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ: IT-00-41-PT, ប្រធានតុលាការ ICTY, ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥, កថាខណ្ឌទី៣ ។

[55] ករណីរបស់ អៀង សារី, កំណត់ហេតុនៃការសាកសួរទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨, ERN 00250650-00250652, C44) ។

៣៦. ដើមបណ្តឹងឧទ្ធរណ៍ទាមទារថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តកិច្ចស៊ើបសួរ ប្រកបដោយការយកចិត្តទុកដាក់នោះទេ ។ ការណ៍នេះ បើយោងតាមរូបគាត់ គឺបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់គាត់សម្រាប់ជាយុត្តិកម្មក្នុងការដោះលែងបណ្តោះអាសន្ន[56] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណុំនៃភស្តុតាងនៅលើសំណុំរឿងនេះ ចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងការចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍មក ដូចបានបញ្ជាក់ខាងលើ បានបដិសេធលើការទាមទារនេះ ។

៣៧. ដើមបណ្តឹងឧទ្ធរណ៍ បាននិងកំពុងទទួលរងនូវ ការស៊ើបសួរចំពោះការទទួលខុសត្រូវដែលជននេះ បានរៀបចំផែនការ បានញុះញង់ បានចេញបញ្ជា បានជួយនិងជម្រុញ ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មខុសៗគ្នាប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ ដោយមានបញ្ចូលបទចោទប្រកាន់អំពី "ការប្រព្រឹត្តិ" ដែលជាការចូលរួមរបស់ដើមបណ្តឹងឧទ្ធរណ៍ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមមួយ ("JCE") ក្នុងនាមជាសហចារីដែលនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនៅក្នុង កម្ពុជាប្រជាធិបតេយ្យទូទាំងកម្ពុជា និងសម្រាប់អាណត្តិពេលវេលាទាំងមូលរបស់តុលាការនេះ ។ អាស្រ័យហេតុនេះ ភស្តុតាងដែលប្រមូលបានដោយសហចៅក្រមស៊ើបអង្កេត គ្របដណ្តប់លើគ្រប់ទម្រង់ទាំងអស់នៃការរួមចំណែករបស់ដើមបណ្តឹងឧទ្ធរណ៍ ចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ ដោយរាប់បញ្ចូលទាំងភស្តុតាងនៅកន្លែងកើតហេតុ ភស្តុតាងដែលភ្ជាប់ កន្លែងកើតហេតុនៃបទឧក្រិដ្ឋទៅនឹងរចនាសម្ព័ន្ធដឹកនាំដែលដើមបណ្តឹងឧទ្ធរណ៍រូបនេះ គឺជា ផ្នែកដ៏សំខាន់ ភស្តុតាងគាំទ្រចំពោះការចូលរួមរបស់គាត់នៅក្នុង JCE ភស្តុតាងគាំទ្រធាតុផ្សំ ខាងផ្នែកយុត្តាធិការ ។ល។

៣៨. ដោយមិនធ្វើឲ្យខូចដល់សារណាដាក់ជូនដែលថា សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវលក្ខខណ្ឌតម្រូវឲ្យមានអំពីការយកចិត្តទុកដាក់ហ្មត់ចត់នោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការមាន ឬមិនមានការយកចិត្តទុកដាក់ហ្មត់ចត់ ពីសំណាក់សហចៅក្រមស៊ើបអង្កេត គឺគ្មាន

---

[56] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១ក ។

អ្វីពាក់ព័ន្ធគ្នាជាមួយនិងការសម្រេចលើការដោះលែងជាបណ្តោះអាសន្ន អនុលោមតាមវិធាន ៦៣(៣)(ក) និង ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងនោះទេ ។

៣៩. បន្ថែមពីលើនេះ យន្តការសិទ្ធិមនុស្សនានាប្រចាំតំបន់ - ដូចជា តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប ("ECHR")- ដែលចាត់ទុកបញ្ហាស្តីពីការយកចិត្តទុកដាក់ហ្មត់ចត់ថាវាពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនៅក្នុងកាលៈទេសៈផ្សេងៗគ្នាជាងតុលាការនេះ។ តុលាការ ECHR ដោះស្រាយជាចំបងលើករណីរឿងក្តីដែលបញ្ជូនមកពីយុត្តាធិការនានារបស់ថ្នាក់ជាតិផ្អែកលើមូលដ្ឋាននៃបទចោទប្រកាន់អំពីបទល្មើសតាមច្បាប់ក្នុងស្រុកនៅក្នុងកាលៈទេសៈដែលមិនមានជម្លោះ។ ម្យ៉ាងទៀត តុលាការនានា ដូចជា អ.វ.ត.ក នេះ គឺជាតុលាការពិសេសដែលត្រូវបានធ្វើឲ្យទៅជាលក្ខណៈអន្តរជាតិ ដើម្បីជំនុំជម្រះក្តីលើករណីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលភាគច្រើនត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុង ឬអន្តរជាតិ និង/ឬ នៅក្នុងបរិបទនៃការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ ឬជាប្រព័ន្ធ ដែលសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គបុរេជំនុំជម្រះ ត្រូវតែពិនិត្យមើលយុត្តិសាស្ត្ររបស់ ECHR ដោយតម្រូវឲ្យមានការប្រុងប្រយ័ត្ន និងគួរតែសម្លឹងមើលទៅយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌពិសេស ឬអចិន្ត្រៃយ៍ទាំងឡាយដែលកំពុងតែជំនុំជម្រះក្តីលើឧក្រិដ្ឋ-កម្មផ្សេងៗដែលមានភាពស្មុគស្មាញ និងមានទំហំដូចគ្នានេះ ។

៤០. សហព្រះរាជអាជ្ញា ក៏បានកត់សម្គាល់ផងដែរថា តុលាការនានាដូចជា ECHR ដោះស្រាយលើករណីរឿងទាំងឡាយ ដែលបញ្ជូនមកពីយុត្តាធិការក្នុងស្រុកនានា ដែលមានការជឿនលឿនខ្លាំងដែលប្រើប្រាស់យន្តការសម្រាប់ស៊ើបអង្កេត និងចោទប្រកាន់ផ្សេងៗដែលបានបង្កើតឡើងនៅក្នុងពេលដែលតុលាការនេះត្រូវធ្វើការដោយប្រើយន្តការស៊ើបអង្កេតមួយថ្មីដែលបានបង្កើតឡើងជាពិសេស។ នេះគឺជាការធ្វើឲ្យតុលាការនេះមានបញ្ហាប្រឈម និងមានភាពស្មុគស្មាញជាក់ស្តែងជាច្រើនរបស់ខ្លួន ។

00273408

C22/5/7



៤១. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះ ធ្វើការបដិសេធចោលនូវអំណះអំណាងស្តីពីការយកចិត្តទុកដាក់ហួតចត់ ដោយសារមិនមានអង្គហេតុគាំទ្រផង និងមិនអាចមានចេរភាពខាងអង្គច្បាប់ផង ។

## ៥. សេចក្តីសន្និដ្ឋាន

៤២. សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គបុរេជំនុំជម្រះបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍នេះ ៕

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០០៨
សហព្រះរាជអាជ្ញា

លោកស្រី ជា លាង — សហព្រះរាជអាជ្ញា

លោក Robert PETIT — សហព្រះរាជអាជ្ញា